# ការជ្រើសរើសមុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ចនៅឃុំប្រស្នឹបដំណើរការបានល្អ



*សកម្មភាពចាក់ផ្សាយសេចក្តីជូនដំណឹងស្តីពីការទទួលពាក្យស្នើសុំដីសម្បទានសង្គមកិច្ចនៅឃុំប្រស្នឹប។*



*លោក ឃុយ ឃី មេឃុំ ប្រស្នឹប*



*គ្រួសារមុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ចពិនិត្យបញ្ជីឈ្មោះអ្នកទទួលដីនៅភូមិត្រពាំងអំពិល ឃុំប្រស្នឹប។*



*ក្រុមការងារចុះផ្ទៀងផ្ទាត់ទិន្នន័យតាមខ្នងផ្ទះ ក្រោយពីមានបណ្តឹងត៉វ៉ា។*

ដំណើរការនៃការជ្រើសរើសមុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ច ក្រោមគម្រោងឡាសិត ៣ នៅឃុំប្រស្នឹប ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង បានចាប់ផ្តើមពីថ្ងៃទី ២៦ ខែមិថុនា ដល់ខែថ្ងៃទី២១ ខែកក្កដា ដោយក្រុមការងារបានធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ហើយបិទផ្សាយនៅផ្ទះប្រធានភូមិ សាលាឃុំ និងទីប្រជុំជន និងជាប្រភេទសារសម្លេងចាក់ផ្សាយតាមមេក្រូនៅតាមទីប្រជុំជននៅទូទាំងឃុំ។

ឃុំប្រស្នឹប មាន៧ភូមិ និងមានប្រជាជនសរុបចំនួន ១.៨៦០គ្រួសារ ដែលក្នុងនោះមាន ១១៦គ្រួសារ ជាប្រភេទគ្រួសារក្រ ១ និង១៨០គ្រួសារ ជាប្រភេទគ្រួសារក្រ ២។ លោក ឃុយ ឃី មេឃុំប្រស្នឹប បានមានប្រសាសន៍ថា យោងតាមបញ្ជីឈ្មោះអ្នកដាក់ពាក្យស្នើសុំដី ដែលរដ្ឋបាលឃុំបានបិទផ្សាយជាសាធារណកាលពីខែសីហា ឆ្នាំ ២០២៣ មានអ្នកដាក់ពាក្យសរុបចំនួន ៥៥៦គ្រួសារ ក្នុងនោះមានគ្រួសារក្រ ១ និងក្រ ២ សរុប ១៥១គ្រួសារ។

យោងលើផែនការប្រើប្រាស់ដីដែលបានអនុម័តដោយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីខេត្តកំពង់ឆ្នាំងកាលពីខែកញ្ញា ឆ្នាំ២០២៣ ផ្ទៃដីទំហំ ៣២២ ហិកតា ត្រូវបានបែងចែកជាប្រភេទដីលំនៅឋានចំនួន ២៤២ឡូត៍ ដែលឡូត៍នីមួយៗ មានទំហំ ៣០ម x ៤០ម និងដីកសិកម្មចំនួន ២២៥ឡូត៍ ដែលឡូត៍នីមួយៗមានទំហំមួយហិកតា។

ផ្អែកលើលក្ខខណ្ឌនៃការដាក់ពិន្ទុ មានអ្នកដាក់ពាក្យតែ ២៤៩គ្រួសារប៉ុណ្ណោះ ត្រូវបានជ្រើសរើសជាមុខសញ្ញាអ្នកទទួលដីអាទិភាព ចំណែកឯ ៣០៧គ្រួសារទៀត ត្រូវជ្រើសរើសជាមុខសញ្ញាអ្នកទទួលដីបម្រុង។ ក្នុងចំណោមមុខសញ្ញាអ្នកទទួលដីអាទិភាព ២៤៩គ្រួសារនោះ មាន២០៧គ្រួសារបានដាក់ពាក្យស្នើសុំទាំងដីលំនៅឋាន និងដីកសិកម្ម ២៤គ្រួសារស្នើសុំតែដីលំនៅឋាន និង ១៨គ្រួសារស្នើសុំដីកសិកម្ម។

លោក ឃី បានពន្យល់ថា នីតិវិធីនៃការជ្រើសរើសគ្រួសារក្រីក្រគ្មានដី និងខ្វះដីពិតប្រាកដ ត្រូវបានរៀបចំធ្វើឡើងប្រកបដោយតម្លាភាព តាមរយៈគណៈកម្មាធិការវាយតម្លៃ និងដាក់ពិន្ទុ ដែលសមាសភាពរួមមាន មេឃុំ ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ប្រធានភូមិ អនុប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យក្នុងភូមិ។ ជនទាំងឡាយណាដែលមិនពេញចិត្តនឹង ដំណើរការនៃការជ្រើសរើសនេះ អាចសរសេរពាក្យបណ្តឹងដាក់ចូលក្នុងប្រអប់ «យន្តការបណ្តឹងត៉វ៉ា» នៅខាងមុខការិយាល័យរដ្ឋបាលឃុំបាន។ គណៈកម្មាធិការដោះស្រាយបណ្តឹងត៉វ៉ា ក៏ទទួលយកនូវបណ្តឹងត៉វ៉ាដោយផ្ទាល់មាត់ផងដែរ។

ក្នុងចំណោមគ្រួសារដែលបានដាក់ពាក្យស្នើសុំដីទាំងអស់មាន១៦គ្រួសារបានដាក់ពាក្យបណ្តឹងមករដ្ឋបាលឃុំ ទាមទារពិនិត្យមើលទិន្នន័យ ដែលក្រុមការងារបានដាក់បញ្ចូលនៅក្នុងទម្រង់ពាក្យស្នើសុំរបស់ពួកគាត់៕